ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករសន្តិសុខសង្គម

SOCIAL SECURITY REGULATOR

គាំពារសង្គមកម្ពុជា

SOCIAL PROTECTION IN CAMBODIA

**និយ័តករសន្តិសុខសង្គម**

លេខ: ......✓....../ ន.ស.ស.......

ថ្ងៃ អង្គារ ២ កើត ខែ មាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មករា ឆ្នាំ២០២៦

# សេចក្តីជូនដំណឹង
## ស្តីពី
## វឌ្ឍនភាពនៃការផ្តល់ការឯកភាពក្នុងការចុះកិច្ចព្រមព្រៀងប្រើប្រាស់ និងផ្តល់សេវាសុខាភិបាល រវាងបេឡាជាតិសន្តិសុខសង្គម និងមូលដ្ឋានសុខាភិបាលឯកជន

**និយ័តករសន្តិសុខសង្គម** (ន.ស.ស.) មានកិត្តិយសសូមជូនដំណឹងដល់សាធារណជន ឱ្យបានជ្រាបថា៖ ដោយអនុលោមតាមច្បាប់ និងបទបញ្ញត្តិជាធរមាន, **និយ័តករសន្តិសុខសង្គម** មានសមត្ថកិច្ចក្នុងការពិនិត្យ និងផ្តល់ការឯកភាពឱ្យបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) ចុះកិច្ចព្រមព្រៀងប្រើប្រាស់ និងផ្តល់សេវាសុខាភិបាលជាមួយមូលដ្ឋានសុខាភិបាលឯកជន ដើម្បីរួមចំណែកពង្រឹងគុណភាពសេវាសុខាភិបាលជូនសមាជិក ប.ស.ស.។ គិតត្រឹមដំណាច់ឆ្នាំ២០២៥ ន.ស.ស. បានផ្តល់ការឯកភាពឱ្យមូលដ្ឋានសុខាភិបាលឯកជនសរុបចំនួន ៥៣ ក្នុងនោះ៖

១- មូលដ្ឋានសុខាភិបាលឯកជនចំនួន៤៩ បាន និងកំពុងចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស. ដើម្បីផ្តល់សេវាសុខាភិបាលដោយស្របច្បាប់ និងតាមនីតិវិធីពេញលេញ និង

២- មូលដ្ឋានសុខាភិបាលឯកជនសរុបចំនួន៤ បានបញ្ចប់កិច្ចព្រមព្រៀងជាមួយ ប.ស.ស. តាមការស្នើសុំរបស់ ប.ស.ស. ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនជ្រាបជាព័ត៌មាន។ **បេឡាជាតិសន្តិសុខសង្គម** ដែលជាស្ថាប័នប្រតិបត្តិករអាចផ្តល់ព័ត៌មានលម្អិតបន្ថែមទៀត អំពីមូលដ្ឋានសុខាភិបាលឯកជនទាំងនេះ។

**និយ័តករសន្តិសុខសង្គម**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA

ទូរសព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666